# ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ព្រះបរមបច្ឆាមរណនាម

## ព្រះបរមរតនកោដ្ឋ

ថ្វាយព្រះបរមសព

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ
ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

ន សីហមុនី

នរោត្តម សីហមុនី

៣៩៧.១២១១.៩៩៣

បានប្រថាប់ព្រះរាជលញ្ឆករហើយ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០៣៦/១២ រ.ចច
ធ្វើនៅភ្នំពេញ ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ ២០១២
សម្តេចចៅហ្វាវាំង ... អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE * LE MINISTRE du PALAIS

ច្បាប់ចម្លង

ព្រះបរមរាជវាំង

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

# សេចក្តីសម្រេច

## របស់អង្គប្រជុំពិភាក្សា អំពីព្រះបរមបច្ឆាមរណនាម ថ្វាយព្រះបរមសព **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅលើព្រះទីនាំងភោជនីយ៍. ព្រះបរមរាជវាំង

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជសវនីយ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅថ្ងៃសៅរ៍ ១១រោច ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ១៣:០០នាទីរសៀល អង្គប្រជុំដូចមានព្រះនាម-នាម ខាងក្រោមនេះ បានពិភាក្សាអំពីព្រះបរមបច្ឆាមរណនាម ថ្វាយ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានមូលមតិសំរេចជាឯកច្ឆ័ន្ទ កំណត់យកពាក្យ :

..........ព្រះបរមរតនកោដ្ឋ..........

ជាព្រះបរមបច្ឆាមរណនាម ថ្វាយព្រះបរមសព **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

អង្គប្រជុំសូមក្រាបបង្គំទូលថ្វាយ សូមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ អំពីព្រះបរមបច្ឆាមរណនាមនេះ និងសូមប្រោសព្រះរាជទានព្រះរាជក្រឹត្យ ថ្វាយព្រះបរមសព ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **នន្ទ ងៀង**
សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី**
សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត**
សម្តេចព្រះធម្មលិខិត **លាស់ ឡាយ**
សម្តេចព្រះពោធិវង្ស **អំ លឹមហេង**
សម្តេចព្រះវិនវត **ណយ ច្រឹក**
សម្តេចព្រះឧត្តមបញ្ញា **ដួង ផង់**
សម្តេចព្រះឧត្តមវង្សា **មួង ភី**
សម្តេចព្រះឧត្តមចរិយា **ឈឹង ប៊ុនឈា**
សម្តេចព្រះមហាអរិយវង្ស **សៅរ៍ ចន្ទថុល**

សម្តេចចៅហ្វាវាំង **គង់ សំអុល**
អ្នកឧកញ៉ាភក្តីព្រះស្តេច **ហេង គឹមគុណ**
ព្រះជយាធិបតី **កង កេន**

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១២